**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

PHNOM PENH WATER SUPPLY AUTHORITY
**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
លេខ...០២៤ស.ន.ណ...

ថ្ងៃ..១៩..៦កើត........ខែមាឃ...ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី..១៧...ខែ..កុម្ភៈ..ឆ្នាំ២០២១

# សេចក្តីជូនដំណឹង
## ស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញនឹងដាក់ឲ្យដេញថ្លៃជាសាធារណៈ ដើម្បីផ្គត់ផ្គង់ថ្នាំប្រតិករគីមី ឧបករណ៍ពិនិត្យគុណភាពទឹក GLASSWARE និងគ្រឿងបន្លាស់។

ឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ (រួមទាំងសេចក្តីណែនាំ) មានដាក់លក់នៅអង្គភាពលទ្ធកម្មរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលមានអាសយដ្ឋានលេខ៤៥ ផ្លូវលេខ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ចាប់ពីថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២១ តទៅ រៀងរាល់ម៉ោងធ្វើការ (៨ព្រឹកដល់១៦:៣០ល្ងាច) ដល់ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១ ត្រឹមវេលាម៉ោង ១៦:០០ល្ងាច ក្នុងមួយច្បាប់តម្លៃ ២០០,០០០រៀល។

កាលបរិច្ឆេទឈប់ទទួល និងបើកសំណើដេញថ្លៃគឺ ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២១ វេលាម៉ោង១៤:១៥នាទី នៅអង្គភាពលទ្ធកម្មរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ជាន់ទី១) តាមអាសយដ្ឋានខាងលើ។

គ្រប់ពាក្យដេញថ្លៃទាំងអស់ ត្រូវភ្ជាប់មកជាមួយនូវប្រាក់កក់ធានាការដេញថ្លៃដែលមានចំនួនដូចបានកំណត់ក្នុងឯកសារដេញថ្លៃ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមាន ប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ (ទូរស័ព្ទទាក់ទងលេខ ០១៧ ៨១១ ៥១១)។

**ជ. គណៈកម្មាធិការលទ្ធកម្ម**
**អនុប្រធានទី១**

**ម៉ា ណូវ៉ាទីន**

ចម្លងជូន៖
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ
"ដើម្បីជ្រាបជាព័ត៌មាន"
-ឯកសារ-កាលប្បវត្តិ